**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**

**លេខ ៣៩៧/០៦ គ.ជ.ប**

# សេចក្តីជូនដំណឹង
## ស្តីពី
## សកម្មភាពផ្សព្វផ្សាយរបស់គណបក្សនយោបាយនៅតាមទីសាធារណៈ ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៦

- យោងព្រះរាជក្រមលេខ ជស/រកម/១១៩៧/០៧ ចុះថ្ងៃទី១៨ ខែវិច្ឆិកា ឆ្នាំ១៩៩៧ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីគណបក្សនយោបាយ ។
- យោងព្រះរាជក្រមលេខ នស/រកម/០៣០១ ចុះថ្ងៃទី១៩ ខែមីនា ឆ្នាំ២០០១ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការគ្រប់គ្រងរដ្ឋបាលឃុំ សង្កាត់ ។

ដើម្បីរក្សាស្ថិរភាព សណ្តាប់ធ្នាប់ របៀបរៀបរយសាធារណៈ និងបង្ការនូវបាតុភាពផ្សេងៗ ក្នុងអំឡុងពេលពិនិត្យបញ្ជីឈ្មោះ និងចុះឈ្មោះបោះឆ្នោតប្រចាំឆ្នាំ ២០០៦ គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សូមជូនដំណឹងដល់គណបក្សនយោបាយទាំងអស់ជ្រាបថា រាល់សកម្មភាពផ្សព្វផ្សាយរបស់គណបក្សនយោបាយនៅតាមទីសាធារណៈ ទោះបីការផ្សព្វផ្សាយនោះ ជាការអប់រំ ឬសេចក្តីអំពាវនាវ ឬខ្លឹមសារនយោបាយក្តី ត្រូវធ្វើការទំនាក់ទំនងជាមួយនឹងអាជ្ញាធរដែនដីរបស់ខ្លួនជាមុនសិន ។

គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត សង្ឃឹមទុកជាមុនថា គណបក្សនយោបាយទាំងអស់ នឹងយកចិត្តទុកដាក់អនុវត្តតាមខ្លឹមសារនៃសេចក្តីជូនដំណឹងនេះឱ្យមានប្រសិទ្ធភាពខ្ពស់ ។

ភ្នំពេញ ថ្ងៃទី ១៧ ខែ តុលា ឆ្នាំ ២០០៦
**ត.ប.គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត**
**អគ្គលេខាធិការ**

**តេព នីថា**

**ចម្លងជូន**
- ក្រសួងមហាផ្ទៃ
"ដើម្បីជូនជ្រាប"
- លខ/កប
- ឯកសារ កាលប្បវត្តិ